01635427

F51/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jan-2020, 14:17
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**

Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សេរីវុឌ្ឍ**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម ម៉ុង មុនីចរិយា**
**ចៅក្រម Maureen Harding CLARK**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២០**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

---

# សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំដាក់ភស្តុតាងបន្ថែម

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Brenda HOLLIS

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Megan HIRST

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន
Anta GUISSÉ

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល” និង “អ.វ.ត.ក”) បានទទួល សំណើរបស់ ខៀវ សំផន សុំដាក់ភស្តុតាងបន្ថែម(“សំណើសុំ”)[1]។

## I. **សាវតារ**

1. នៅថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៨ ដោយផ្អែកលើកាតព្វកិច្ចក្នុងការបង្ហាញភស្តុតាង សហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើសុំឱ្យបង្ហាញឯកសារមួយចំនួននៅក្នុងសំណុំរឿង ០០៣ និង ០០៤[2]។

2. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ដោយបានសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយបានសម្រេចដាក់ទោស នួន ជា និង ខៀវ សំផន ឱ្យជាប់ពន្ធនាគារអស់មួយជីវិត[3]។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងអំពីសាលក្រមដែលមានសម្អាងហេតុពេញលេញ ជាភាសាខ្មែរ អង់គ្លេស និងបារាំងនឹងចេញនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ (“សាលក្រមអង្គជំនុំជម្រះសាលាដំបូង”)[4]។

3. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង និងបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលមោឃភាពសេចក្តីសង្ខេបដែលបានចេញនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ដោយសារមិនមានលក្ខណៈពេញ

---

[1] សំណើរបស់ ខៀវ សំផន សុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F51 (“សំណើសុំដាក់ភស្តុតាង”)។

[2] សំណើសុំបង្ហាញភស្តុតាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិចេញពីសំណុំរឿង ០០៣ និង ០០៤ ឯកសារលេខ E319/71 (“ឯកសារត្រូវបានបង្ហាញ”) ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៨។

[3] *សូមមើលប្រៀបធៀបសំណុំរឿង* ០០២/០២ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/259.1 (ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២) ទំព័រ ៣៨ (ជួរ ២៥) ដល់ ៤១ (ជួរ ១០)។

[4] អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ដោយសារសាលក្រមនេះពុំត្រូវបានដាក់ក្នុងម៉ោងធ្វើការជាផ្លូវការរបស់ អ.វ.ត.ក. ដូច្នេះសេចក្តីជូនដំណឹងនៃសាលក្រមនេះមានអានុភាពគិតចាប់ពីថ្ងៃធ្វើការបន្ទាប់ពីថ្ងៃដាក់នោះ គឺចាប់ពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩។

លេញតាមទម្រង់ និងសុំឱ្យប្រកាសថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលចេញពេលក្រោយមកទៀតនោះ ទៅជាមោឃៈ[5]។ នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា បណ្តឹងសាទុក្ខភ្លាមៗនោះពុំអាចទទួលយកបាន[6]។

4. បន្ទាប់មកទៀត អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមដែលមានសំអាងហេតុពេញលេញជាភាសាខ្មែរ អង់គ្លេស និងបារាំង នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ ("សាលក្រមអង្គជំនុំជម្រះសាលាដំបូង")[7]។

5. នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង[8]។ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតផ្តល់ឱ្យភាគីនូវការបន្ថែមពេលវេលា និងចំនួនទំព័រជារួមដូចគ្នានៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩[9]។

6. នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួនដោយបានលើកទឡ្ហីករណ៍មួយនៃបណ្តឹងសាទុក្ខ[10]។

---

[5] បណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E463/1។

[6] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលបានប្រកាសនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៩ ឯកសារលេខ E463/1/3។

[7] សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F43 កថាខណ្ឌ ១២។

[8] សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F39/1.1។

[9] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F43។

[10] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩ ឯកសារលេខ E465/2/1 ("សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា")។

7. នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ និងបានលើកកំហុសយ៉ាងតិចចំនួន ១.៨២៤ ដែលបានចោទថាអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្ត[11]។

8. នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់សំណើសុំឱ្យទទួលយកភស្តុតាងបន្ថែម ("សំណើសុំ")[12]។

9. នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៩ សហព្រះរាជអាជ្ញាបានដាក់សារណាតបទៅនឹងសំណើសុំនេះ[13]។

10. នៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់ការឆ្លើយតបរបស់ខ្លួនទៅនឹងសារណាតប[14]។

## II. ច្បាប់ជាធរមាន

11. នៅក្នុងក្របខ័ណ្ឌការងារនៃ អ.វ.ត.ក. ការទទួលយកភស្តុតាងថ្មីលើបណ្តឹងសាទុក្ខត្រូវអនុលោមតាមវិធាន ១០៤(១) និង ១០៨(៧) នៃវិធានផ្ទៃក្នុង។ យោងតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចពិនិត្យភស្តុតាងដោយខ្លួនឯងផ្ទាល់ និងអាចស្នើឱ្យដាក់ភស្តុតាងថ្មីដើម្បីសម្រេចលើបណ្តឹងសាទុក្ខណាមួយបាន។ វិធាន ១០៨(៧) ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា៖

> យោងតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ភាគីអាចស្នើមកអង្គជំនុំជម្រះ សុំដាក់ភស្តុតាងបន្ថែមប្រសិនបើភស្តុតាងនោះពុំអាចរកបាននៅមុនការជំនុំជម្រះ និងអាចជាកត្តាសំខាន់ក្នុងការធ្វើសេចក្តីសម្រេចនេះពេលជំនុំជម្រះ។ សំណើសុំនេះត្រូវកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់នូវការយល់ឃើញជាក់លាក់ផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ដែលភស្តុតាងបន្ថែមនេះចង់សំដៅ

---

[11] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/3/1។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២) ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/4/1។

[12] សំណើរបស់ ខៀវ សំផន សុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ០៨ ខែ តុលា ឆ្នា ២០១៩ ឯកសារលេខ F51 ("សុំដាក់ភស្តុតាងបន្ថែម")។

[13] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F51/1 ("សារណាតប")។

[14] ការឆ្លើយតបរបស់ ខៀវ សំផន ទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើសុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៩ F51/2, ("ការឆ្លើយតប")។

ទៅលើនោះ។ ភាគីដទៃទៀតដែលប៉ះពាល់ដោយសារសំណើនេះអាចឆ្លើយតបក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃបន្ទាប់ពីទទួលបានការជូនដំណឹងនៃសំណើនេះ។

12. អង្គជំនុំជម្រះបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនតាំងពីដំបូងក្នុងការទទួលយកភស្តុតាងថ្មី ដោយអនុលោមតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០១[15]។

## III. សំណើរបស់មេធាវីការពារក្តី

13. មេធាវីការពារក្តីបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលទទួលយកភស្តុតាងថ្មីនៃកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីឈ្មោះ ឯក ហេន និង ជួន ធី ដែលត្រូវបានរកឃើញនៅក្នុងសំណុំរឿង ០០៣ និង ០០៤។ បន្ថែមលើនេះ មេធាវីការពារក្តីបានស្នើសុំការបង្ហាញជាខ្សែអាត់ថតសំលេងនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីនេះ[16]។

## IV. ភស្តុតាងបន្ថែម

14. ភស្តុតាងបន្ថែមដែលស្នើសុំនេះ មានកំណត់ហេតុស្តាប់ចម្លើយសាក្សីពីររូបឈ្មោះ ឯក ហេន និង ជួន ធី ដែលបានធ្វើឡើយដោយការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត សម្រាប់ជាផ្នែកមួយនៃសំណុំរឿង ០០៣ និង ០០៤ ហើយត្រូវបានបង្ហាញដោយសហព្រះរាជអាជ្ញាអន្តរជាតិឱ្យមេធាវីការពារក្តី និងអង្គជំនុំជម្រះសាលាដំបូងបានឃើញបន្ទាប់ពីការបញ្ចប់លើការពិនិត្យឡើងវិញនូវភស្តុតាងនៅក្នុងសំណុំរឿងទាំងពីរខាងលើដោយគោរពតាមកាតព្វកិច្ចក្នុងការបង្ហាញភស្តុតាងទាំងអស់របស់អយ្យការ[17]។

[15] *រឿងក្តី ព្រះរាជអាជ្ញា ទល់នឹង កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ 001/18-07-2007-ECCC/SC សេចក្តីសម្រេចលើសំណើបន្ថែមរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ សុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ F2/5/1។ *រឿងក្តី ព្រះរាជអាជ្ញា ទល់នឹង កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ 001/18-07-2007-ECCC/SC សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តី និងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១, ២, ៣ សុំដាក់ភស្តុតាងបន្ថែម ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ F2/4។

[16] សំណើសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ៥។

[17] ឯកសារដែលបានបង្ហាញលេខ E319/71 កថាខណ្ឌ ១។

15. ជាសរុប ឯក ហេន គឺជាកសិករ បានចូលធ្វើការក្នុងមជ្ឈមណ្ឌលមួយចំនួនក្នុងរបបខ្មែរក្រហម។ កំណត់ហេតុរបស់គាត់ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌការងារ និងការរស់នៅ ការសាមគ្គី និងវគ្គសិក្សា (អប់រំ)នៅបូរីកីឡា និងកម្មវត្ថុស្តីពីប្រជាជនដែលត្រូវបានចាត់ទុកថាជា ជនក្បត់ ដូចជា ប៉ង់[18]។

16. ចំណែកសាក្សី ជួន ធី ហៅ ធី ឬ ធី ឌី គឺជាអតីតមេបញ្ជាការកងវរសេនាតូចភូមិភាគបស្ចិម ដែលសក្ខីកម្មរបស់គាត់ផ្តោតទៅលើបទបញ្ជារៀបអាពាហ៍ពិពាហ៍[19]។

## V. សារណា

*ខៀវ សំផន*

17. មេធាវីការពារក្តីបានលើកឡើងថា សវនាការក្នុងសំណុំរឿង ០០២/០២ បានបញ្ចប់នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧ ហើយនៅថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៨ ខណៈពេលដែលអង្គជំនុំជម្រះសាលាដំបូងបានចាប់ផ្តើមពិភាក្សាសម្រេចលើសាលក្រម សហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញឯកសារចំនួនប្រាំបីចេញពីសំណុំរឿង ០០៣ និង ០០៤ ដែលមានកំណត់ហេតុស្តាប់ចម្លើយសាក្សីពីររូបឈ្មោះ ឯក ហេន និង ជួន ធី ដែលចុះកាលបរិច្ឆេទថ្ងៃទី ២៨ ខែ កុម្ភៈ និងខែ មីនា ឆ្នាំ ២០១៧[20]។

18. មេធាវីការពារក្តីបានលើកឡើងថា អយ្យការខកខានក្នុងការបំពេញកាតព្វកិច្ចបង្ហាញភស្តុតាងដោយអនុលោមតាមវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង និងក្នុងការយកចិត្តទុកដាក់បង្ហាញឯកសារដែលអាចជាភស្តុតាងដោះបន្ទុក ភ្លាមៗបន្ទាប់ពីមានការដឹងឮ ជាពិសេសថា សាក្សីទាំងពីររូបនេះពីដើមឡើយបានមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០៣ និង ០០៤[21]។ មេធាវីការពារក្តីបានអះអាងថា នៅពេលដែលអយ្យការគ្រប់ដណ្តប់យ៉ាងសន្ធប់មកលើខ្លួនដោយបញ្ចូលភស្តុតាងថ្មីដាក់បន្ទុកមកជាមួយផងនោះ អយ្យការពុំបានលើកបង្ហាញអំពីកំណត់ហេតុស្តាប់ចម្លើយទាំងនោះដែលយកមកសំអាងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួនឡើយ។ មេធា

[18] សំណើសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ១៦, ២២, ២៤ ដល់ ២៨ *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារលេខ E1/217. 1 ទំព័រ ១០, ២១ ដល់ ២៣, ៣៤, ៣៥ ដល់ ៣៨។

[19] សំណើសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ៥៥ ដល់ ៥៦ (៥៧ ដល់ ៧៣) *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ ឯកសារលេខ E1/183.1 ទំព័រ ៨ ដល់ ២០។

[20] សំណើសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ៩ *សូមមើលផងដែរ* ឯកសារលេខ E319/71.2.7 និង E319/71.2.4។

[21] សំណើសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ១០ *សូមមើលផងដែរ* ឯកសារលេខ E319/71, E319/71.2, E363/3, E421/4។

វីការពារក្តីបានអះអាងបន្ថែមទៀតថា ខ្លួនអាចប្រើប្រាស់ភស្តុតាងនេះដើម្បីជំទាស់ភាពអាចជឿទុកចិត្តបានរបស់ ឯក ហេន ឬសំអាងលើ ជួន ធី ដើម្បីគាំទ្ររឿងក្តីរបស់ខ្លួន។ មេធាវីបានកត់សម្គាល់ផងដែរថា ប្រសិនបើសហព្រះរាជអាជ្ញាបានបង្ហាញកំណត់ហេតុស្តាប់ចម្លើយនេះ នៅមុនពេលការបញ្ចប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះ មេធាវីការពារក្តីអាចនឹងស្នើសុំឱ្យទទួលយកជាភស្តុតាង[22]។

19. តាមមេធាវីការពារក្តីបានឱ្យដឹងថា អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែមានកាតព្វកិច្ចបើកសំណុំរឿងឡើងវិញដោយសារសាក្សីបានផ្តល់សក្ខីកម្មនៅចំពោះមុខខ្លួនប៉ុណ្ណោះទេ ថែមទាំងដោយសារអង្គជំនុំជម្រះបានបញ្ជាក់នូវការអនុវត្តន៍ថា ដើម្បីជាប្រយោជន៍យុត្តិធម៌ និងបញ្ជាក់ការពិតដែលថា ការទទួលយកភស្តុតាងមុន និងក្រោយរបស់សាក្សីសម្រាប់បញ្ហានេះ គឺបានអនុញ្ញាតឱ្យភាគីធ្វើការវាយតម្លៃពេញលេញលើភាពអាចជឿទុកចិត្តបាន និងភាពស៊ីសង្វាក់គ្នានៃការលើកឡើងរបស់សាក្សី[23]។

20. ក្នុងការគាំទ្រជំហររបស់ខ្លួន មេធាវីការពារក្តីបានបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងជាធម្មតាបានស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យបង្ហាញឯកសារដើម្បីឱ្យភាគីអាចវាយតម្លៃបាន ប៉ុន្តែដោយអនុលោមតាមវិធាន ៩៦(២) នៃវិធានផ្ទៃក្នុង ភាគីពុំអាចដាក់សារណា នៅពេលអង្គជំនុំជម្រះស្ថិតក្នុងដំណាក់កាលពិភាក្សាសម្រេច លើកលែងតែអង្គជំនុំជម្រះបើកកិច្ចដំណើរការនីតិវិធីនៃរឿងក្តីសាឡើងវិញប៉ុណ្ណោះ។ មេធាវីការពារក្តីបានអះអាងថា ដោយហេតុនេះ ខ្លួនត្រូវបានរារាំងក្នុងការជំទាស់ទៅនឹងខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីនេះ ឬសួរដេញដោលអំពីភាពអាចជឿទុកចិត្តបានរបស់សាក្សី[24]។ មេធាវីការពារក្តីបានកត់សម្គាល់ថា "ឯក ហេន គឺជាសាក្សីដ៏សំខាន់ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់សម្រាប់ដាក់ពិរុទ្ធភាពលើ ខៀវ សំផន" ខណៈពេលដែល"ចម្លើយដោះបន្ទុករបស់ ជួន ធី ពុំត្រូវបានយកចិត្តទុកដាក់ ឬត្រូវបានប្រើប្រាស់ត្រឹមតែមួយផ្នែកប៉ុណ្ណោះនៅក្នុងការដាក់បន្ទុកជនជាប់ចោទ"។ អាស្រ័យហេតុនេះ មេធាវីការពារក្តីស្នើសុំឱ្យទទួលយកភស្តុតាងនេះនៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ[25]។

---

[22] សំណើសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ១១ *សូមមើលផងដែរ* ឯកសារលេខ E457/6/4, E457/6/1។

[23] សំណើសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ១២ *សូមមើលផងដែរ* ឯកសារលេខ E319/71/1, E319/68/1, E319/69, E319/67, E363/3។

[24] សំណើសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ១៣។

[25] សំណើសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ១៤។

21. ទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់ ឯក ហេន មេធាវីការពារក្តីបានអះអាងថា ភស្តុតាងបន្ថែមនេះអាចជាកត្តាសំខាន់ក្នុងការធ្វើសេចក្តីសម្រេចនៅពេលជំនុំជម្រះ។ ក្នុងការគាំទ្រអំណះអំណាងរបស់ខ្លួន មេធាវីការពារក្តីបានបញ្ជាក់សាជាថ្មីថា កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក ហេន ខ្វះភាពអាចជឿទុកចិត្តបាន នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកសាក្សីរូបនេះថា អាចជឿទុកចិត្តបាន និងសំខាន់បំផុត និងបានយោងទៅលើគាត់យ៉ាងតិចចំនួនប្រាំបួនដងនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ មេធាវីការពារក្តីបានលើកឡើងថា វិសាលភាពនៃភស្តុតាងរបស់គាត់បានគ្រប់ដណ្តប់លើវគ្គបណ្តុះបណ្តាលផ្នែកនយោបាយដែលបានចូលរួម និងបង្រៀនដោយ ខៀវ សំផន នៅបូរីកីឡា ដែលមេធាវីការពារក្តីកត់សម្គាល់ឃើញថា គឺជាកត្តាសំខាន់ក្នុងការសម្រេចអំពីពិរុទ្ធភាពរបស់ ខៀវ សំផន ទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ តួនាទី ការបង្កើតផែនការការអនុវត្តន៍គោលបំណងរួម[26]។ យោងតាមមេធាវីការពារក្តីបានឱ្យដឹងថា មានភាពពុំស៊ីសង្វាក់គ្នាមួយចំនួននៅក្នុងភស្តុតាងរបស់ ឯក ហេន ដូចជាពេលវេលានៃការបណ្តុះបណ្តាលផ្នែកនយោបាយនៅបូរីកីឡា និងនៅពេលដែល ខៀវ សំផន ឬ នួន ជា មានវត្តមាន ប៉ុន្តែខណៈពេលរំលឹកឡើងវិញជាច្រើនដង ឯក ហេន បានបង្ហាញពីបញ្ហាក្នុងការចងចាំរបស់គាត់[27]។

22. មេធាវីការពារក្តីបានអះអាងថា ភស្តុតាងរបស់ ជួន ធី ដែលបានផ្តល់សក្ខីកម្មលើបញ្ហារៀបអាពាហ៍ពិពាហ៍ដោយកត់សម្គាល់ថា ប្រជាជនមានសេរីភាពក្នុងការរៀបការ ពុំត្រូវបានយកមកពិចារណា ហើយចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងសម្រេចដាក់ពិរុទ្ធភាព ខៀវ សំផន ដោយសារការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅក្នុងបរិបទនៃការរៀបការដោយបង្ខំ។ មេធាវីការពារក្តីបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មានអត្ថិភាពនៃគោលនយោបាយដែលដាក់បទបញ្ជាលើការរៀបការ ចំណែកភស្តុតាងរបស់ ជួន ធី មានលក្ខណៈផ្ទុយទៅនឹងកំណត់សំគាល់នេះ[28]។

*សហព្រះរាជអាជ្ញាអន្តរជាតិ*

---

[26] សំណើសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ១៥, ១៦, ៣០ ដល់ ៥៤ *សូមមើលផងដែរ* ឯកសារលេខ E465 & F17។

[27] សំណើសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ១៨ ដល់ ២៥។

[28] សំណើសុំដាក់ភស្តុតាងបន្ថែម កថាខណ្ឌ ៥៥ ដល់ ៥៧។

23. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា សំណើសុំទទួលយកភស្តុតាងរបស់មេធាវីការពារក្តី យឺតពេល ដូច្នេះហើយគប្បីត្រូវបដិសេធចោល។ អយ្យការអះអាងថា អង្គជំនុំជម្រះសាលាដំបូងបាន រំពឹងទុកអំពីការបង្ហាញថានឹងកើតមាន ហើយបានទុករយៈពេលពីរសប្តាហ៍ដើម្បីអនុញ្ញាតឱ្យភាគីដាក់ សារណាតបបន្ទាប់ពីទទួលបានការបង្ហាញភស្តុតាងនោះ[29]។ អយ្យការអះអាងថា កាតព្វកិច្ចនៃការ បង្ហាញរបស់ខ្លួន ត្រូវតែពិចារណាជាប់ពាក់ព័ន្ធទៅនឹង“សិទ្ធិមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួល បានភស្តុតាងដែលមានសក្តានុពលដោះបន្ទុក”[30]។

24. អយ្យការបានលើកឡើងថា មេធាវីការពារក្តីខកខានក្នុងការដាក់សំណើសុំឱ្យទទួលយកភស្តុតាងបន្ទាប់ ពីការលើកបង្ហាញភស្តុតាងនៅថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៨ បើទោះបីជាខ្លួនបានទទួលភស្តុតាងទាំង នេះអស់រយៈពេលពីរខែនៅមុនពេលការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ។ អយ្យការអះអាងថា មេធាវីការពារក្តីមានសិទ្ធិស្នើសុំឱ្យទទួលយកភស្តុតាងដែលបានបង្ហាញនោះដោយ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដោយសារមេធាវីការពារក្តីស្ថិតក្នុងស្ថានភាពល្អបំផុត ក្នុងការកំណត់ថា តើភស្តុតាងទាំងនោះមានលក្ខណៈដោះបន្ទុក ដែរ ឬយ៉ាងណា។ ដូច្នេះអយ្យការលើក ឡើងថា ការអះអាងរបស់មេធាវីដែលថា អង្គជំនុំជម្រះសាលាដំបូងគប្បីបើកកិច្ចដំណើរការនីតិវិធីរឿង ក្តីឡើងវិញ ពុំយកជាបានការនោះទេ ដោយសារការទទួលខុសត្រូវ គឺស្ថិតលើមេធាវីខ្លួនឯងជាអ្នក ស្នើសុំ[31]។

25. អយ្យការបានលើកឡើងថា ភស្តុតាងដែលបានស្នើសុំនោះ ពុំមែនជាកត្តាសំខាន់ក្នុងការសម្រេចសាល ក្រមអង្គជំនុំជម្រះសាលាដំបូងឡើយ។ អយ្យការអះអាងថា សំណើសុំឱ្យទទួលយកជាភស្តុតាង ពុំបាន គោរពតាមបទដ្ឋានស្តីពីភាពអាចទទួលយកបាននៃភស្តុតាងថ្មីនៅដំណាក់កាលបណ្តឹងសាទុក្ខឡើយ។ អយ្យការបន្ថែមទៀតថា មេធាវីការពារក្តីខកខានក្នុងការបង្ហាញលទ្ធភាពជាក់ស្តែងដែលថា ប្រសិន បើភស្តុតាងនេះមានអត្ថិភាពនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ប្រាកដជាមានការសម្រេចសាល ក្រមមួយផ្សេង[32]។

---

[29] សារណាតប កថាខណ្ឌ ១៧។

[30] សារណាតប កថាខណ្ឌ ១៨ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើពាក់ព័ន្ធទៅនឹងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារលេខ E421/4 កថាខណ្ឌ ៩, ២១។

[31] សារណាតប កថាខណ្ឌ ១២ ដល់ ២០។

[32] សារណាតប កថាខណ្ឌ ២១។

26. ទាក់ទងទៅនឹងភស្តុតាងថ្មីរបស់ ឯក ហេន អយ្យការបានអះអាងថា ចម្លើយរបស់សាក្សី និង ការផ្តល់សក្ខីកម្មនៅចំពោះសំណុំរឿង ០០២/០១ ត្រូវបានទទួលយកក្នុងសំណុំរឿង ០០២/០២ ដូចនេះ ការដែលមេធាវីការពារក្តីលើកឡើងថា ឯក ហេន ខ្វះភាពអាចជឿជាក់បាននោះ ពុំត្រឹមត្រូវឡើយ ដោយសារភាពពុំស៊ីសង្វាក់គ្នាទាំងឡាយត្រូវបានដោះស្រាយដោយអង្គជំនុំជម្រះសាលាដំបូង[33]។ អយ្យការបានអះអាងថា ភាពសមហេតុផលនៃការវាយតម្លៃរបស់អង្គជំនុំជម្រះ គឺជាបញ្ហាសម្រាប់បណ្តឹងសាទុក្ខ។ ដូច្នេះ អយ្យការលើកឡើងថា ភស្តុតាងថ្មីរបស់ ឯក ហេន ជាធម្មតា គាំទ្រការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ពីព្រោះពុំមានលទ្ធភាពជាក់ស្តែងកើតមានដែលនាំឱ្យមានការសម្រេចមួយផ្សេងឡើយ[34]។ ការយល់ឃើញចំនួនប្រាំបួនដែលមេធាវីការក្តីបានលើកឡើងនោះ ជាធម្មតាត្រូវបានគាំទ្រដោយភស្តុតាងថ្មីរបស់ ឯក ហេន[35]។

27. អយ្យការបានកត់សម្គាល់ថា សេចក្តីសន្និដ្ឋានពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវរបស់ ខៀវ សំផន គឺផ្អែកលើភស្តុតាងទាំងមូលជារួម ជាឧទាហរណ៍សក្ខីកម្មរបស់ ឯក ហេន ទាក់ទងទៅនឹងកិច្ចប្រជុំនៅបូរីកីឡា ឬការយល់ដឹងរបស់ ខៀវ សំផន អំពីគោលនយោបាយ និង/ឬ លំនាំនៃការប្រព្រឹត្តក្នុងចំណោមដទៃទៀតដែលបានរៀបរាប់ដោយមេធាវីការពារក្តី។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភស្តុតាងផ្សេងៗនៅមុនពេលធ្វើសេចក្តីសន្និដ្ឋានថា ខៀវ សំផន មានការយល់ដឹងតាមលក្ខខណ្ឌតម្រូវអំពីទម្រង់ផ្សេងៗនៃការទទួលខុសត្រូវ[36]។ ដូច្នេះ ភស្តុតាងថ្មីរបស់ ឯក ហេន ពុំបាននាំឱ្យមានការសម្រេចផ្សេងឡើយ[37]។

28. ទាក់ទងទៅនឹងភស្តុតាងថ្មីរបស់ ជួន ធី អយ្យការបានលើកឡើងថា មានលក្ខណៈច្រំដែល ដូចនេះពុំស្របតាមលក្ខខណ្ឌតម្រូវស្តីពីភាពអាចទទួលយកបានដោយអនុលោមតាមវិធាន ៨៧(៣) និង ១០៨(៧) នៃវិធានផ្ទៃក្នុង។ អយ្យការបានអះអាងថា ភស្តុតាងនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងសក្ខីកម្មរបស់ ជួន ធី នៅពេលជំនុំជម្រះ[38] ដែលត្រូវបានគាំទ្រដោយសាក្សី ឯក ហឿន និង

[33] សារណាតប កថាខណ្ឌ ២៣។

[34] សារណាតប កថាខណ្ឌ ២៤។

[35] សារណាតប កថាខណ្ឌ ២៥។

[36] សារណាតប កថាខណ្ឌ ២៧។

[37] សារណាតប កថាខណ្ឌ ២៨។

[38] សារណាតប កថាខណ្ឌ ២៩ ដល់ ៣៤។ *សូមមើលផងដែរ* ឯកសារលេខ E3/10713, E1/183.1, E1/489.1, E1/490.1។

ស៊ូ សឿង[39]។ ដូច្នេះ ពុំមានលទ្ធភាពជាក់ស្តែងដែលថា ភស្តុតាងច្រំដែលរបស់ ជួន ធី អាចនាំឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចផ្សេងនោះឡើយ[40]។

29. អយ្យការបានបង្ហាញពីក្តីបារម្ភរបស់ខ្លួនទៅលើ"ភាពរំជើបរំជួលចិត្តហួសហេតុ និង [...] ភាសាគ្រោតគ្រាតដែលមេធាវីការពារក្តីបានប្រើប្រាស់នៅក្នុងសំណើសុំឱ្យទទួលយកភស្តុតាង" ជាពិសេស ទាក់ទងទៅនឹង"ការចោទប្រកាន់ដែលថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសវិជ្ជាជីវៈក្នុងការដោះស្រាយរឿងក្តី"។ ជាសរុប អយ្យការបានអះអាងថា ការចោទប្រកាន់ទាំងឡាយនេះមានអានុភាពប៉ះពាល់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង[41]។

*ការឆ្លើយតបរបស់មេធាវីការពារក្តី*

30. មេធាវីការពារក្តីបានលើកឡើងថា ទាំងនេះគឺដើម្បីជាប្រយោជន៍យុត្តិធម៌ក្នុងការទទួលយកកំណត់ហេតុស្តាប់ចម្លើយខាងលើ ដើម្បីវាយតម្លៃភាពអាចជឿជាក់បានរបស់សាក្សី។ មេធាវីបានកត់សម្គាល់ផងដែរថា ភាគីដទៃទៀតបានដាក់សំណើប្រហាក់ប្រហែលនេះកន្លងមក ប៉ុន្តែគ្មានការជំទាស់ឡើយ[42]។ មេធាវីក៏បានកត់សម្គាល់បន្ថែមថា អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលបានទទួលយកចម្លើយប្រហាក់ប្រហែលគ្នានេះដែរទៅតាមការស្នើសុំរបស់ភាគី ឬ*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន*[43]។

31. មេធាវីការពារក្តីបានអះអាងថា សាក្សីមានលក្ខណៈប៉ះពាល់យ៉ាងខ្លាំងទៅលើភាពជឿជាក់បាន និងទុកចិត្តនៃសក្ខីកម្មរបស់ខ្លួន ដូច្នេះ កំណត់ហេតុស្តាប់ចម្លើយគប្បីត្រូវទទួលយកជាភស្តុតាងនៅដំណាក់កាលបណ្តឹងសាទុក្ខ[44]។

## VI. **ការពិភាក្សាសម្រេច**

---

[39] *សូមមើលផងដែរ* ឯកសារលេខ E1/299.1, E1/310.1។

[40] សារណាតប កថាខណ្ឌ ៣៥ ដល់ ៤០។

[41] សារណាតប កថាខណ្ឌ ៤១។

[42] ការឆ្លើយតប កថាខណ្ឌ ៤ ដល់ ៥។

[43] ការឆ្លើយតប កថាខណ្ឌ ៦។

[44] ការឆ្លើយតប កថាខណ្ឌ ៨។

32. ជាការកត់សម្គាល់បឋម អង្គជំនុំជម្រះសង្កេតឃើញថា មេធាវីការពារក្ដីបានចោទប្រកាន់ថា អយ្យការមានការធ្វេសប្រហែសដោយសារការ"យឺតយ៉ាវ"របស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការបង្ហាញកំណត់ហេតុស្ដាប់ចម្លើយរបស់ ឯក ហេន និង ជួន ធី។ អង្គជំនុំជម្រះរំលឹកថា វិធានផ្ទៃក្នុងបានដាក់កាតព្វកិច្ចដល់អយ្យការក្នុងការបង្ហាញភស្តុតាងផ្សេងៗរួមទាំងភស្តុតាងដោះបន្ទុក[45]។ ជាការកត់សម្គាល់ អយ្យការបានរំលឹកនូវសេចក្ដីសម្រេចពីដំបូងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបានរៀបរាប់ត្រួសៗអំពីនីតិវិធីថ្មីសម្រាប់បង្ហាញភស្តុតាងចេញពីសំណុំរឿង ០០៣ និង ០០៤ ចូលទៅក្នុងសំណុំរឿង ០០២[46]។ នៅក្នុងសេចក្ដីសម្រេចនោះ ការអនុញ្ញាតជាទូទៅបានផ្ដល់ឱ្យទៅអយ្យការក្នុងការ"បង្ហាញភស្តុតាងណាមួយដែលខ្លួនមានបំណងស្នើសុំបង្ហាញ រួមជាមួយនឹងសេចក្ដីព្រាងនៃសំណើសុំបង្ហាញពេញលេញផងនោះ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល និងមេធាវីការពារក្ដីក្នុងសំណុំរឿង ០០២ ក្រោមលក្ខខណ្ឌនៃភាពសម្ងាត់បំផុត [...] ដើម្បីឱ្យអង្គជំនុំជម្រះដែលទទួលបាន និងមេធាវីការពារក្ដី អាចវាយតម្លៃលើបញ្ហាថា តើភស្តុតាងដែលបានស្នើសុំនោះស្របតាមលក្ខណៈវិនិច្ឆ័យដូចបានកំណត់នៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែរឬយ៉ាងណា"[47]។ ទាំងនេះពុំមែនក្នុងគោលបំណងអនុញ្ញាតឱ្យជាទូទៅនោះទេ ពីព្រោះការអនុញ្ញាតនេះពុំបានលាតសន្ធឹងដល់ការដាក់ភស្តុតាងណាមួយនៅក្នុងសំណុំរឿងឡើយ ហើយក៏ពុំបានអនុញ្ញាតឱ្យមានការចែកចាយភស្តុតាងដល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ដោយគ្មានការយល់ព្រមជាផ្លូវការនោះដែរ[48]។ រាល់សំណើសុំការបង្ហាញទាំងអស់ដោយសហព្រះរាជអាជ្ញាអន្តរជាតិត្រូវធ្វើទៅតាមការយល់ព្រមរបស់អង្គជំនុំជម្រះសាលាដំបូង[49]។

33. ដោយផ្អែកលើការសង្កេតខាងលើ និងដោយពិចារណាទៅលើកាតព្វកិច្ចក្នុងការបង្ហាញបន្តបន្ទាប់របស់អយ្យការ អង្គជំនុំជម្រះពុំបានចាត់ទុកថា សហព្រះរាជអាជ្ញាអន្តរជាតិមានកំហុសទាក់ទងនឹងពេលវេលា ដែលខ្លួនត្រូវស្នើសុំបង្ហាញភស្តុតាងដែលរងការជំទាស់នេះទេ។ ប៉ុន្តែ ដោយពិចារណាលើជំហរ

---

[45] វិធាន ៥៣ នៃវិធានផ្ទៃក្នុង។

[46] សេចក្ដីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបង្កើតកាលវិភាគពេលវេលាសម្រាប់សំណើសុំបង្ហាញភស្តុតាងពីសំណុំរឿង ០០៤ ("សេចក្ដីសម្រេចបង្ហាញភស្តុតាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ") ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ ឯកសារលេខ E319/62 កថាខណ្ឌ ៣០។

[47] សេចក្ដីសម្រេចបង្ហាញភស្តុតាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣០(ក)(i)។

[48] សេចក្ដីសម្រេចបង្ហាញភស្តុតាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ៣០(ក)(i) និង (ii)។

[49] សេចក្ដីសម្រេចបង្ហាញភស្តុតាងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣០(ក)(v)។

របស់មេធាវីការពារក្ដី អង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងដោះបន្ទុកណាមួយដែលត្រូវបានស្នើសុំឱ្យទទួលយកជាភស្តុតាង គប្បីធ្វើឡើងតាមលក្ខណៈមួយដែលងាយស្រួល និងអាចឱ្យមេធាវីការពារក្ដីចូលមើលបាន ជាពិសេសដោយសារមេធាវីការពារក្ដីបានលើកឡើងអំពីទម្ងន់ដែលភស្តុតាងនោះអាចមាន។ អាស្រ័យហេតុនេះ កាតព្វកិច្ចបង្ហាញរបស់អយ្យការត្រូវតែពិចារណាដោយផ្អែកលើ'សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការដែលអាចចូលមើលភស្តុតាងដោះបន្ទុកដែលមានសក្ដានុពល'[50]។

34. អង្គជំនុំជម្រះតុលាការកំពូលមានការប្រុងប្រយ័ត្នជៀសវាងការពិចារណាណាមួយលើបញ្ហា នៅមុនពេលដែលបញ្ហាជាចុងក្រោយនឹងត្រូវសម្រេចនៅដំណាក់កាលបណ្ដឹងសាទុក្ខ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះជៀសវាងផ្ដល់អនុសាសន៍លើទម្ងន់ ឬអ្វីផ្សេង ដែលភ្ជាប់ជាមួយនឹងភស្តុតាងបន្ថែមរបស់ ឯក ហេន ឬ ជួន ធី ឬលើបញ្ហាទម្ងន់ ឬសេចក្ដីសន្និដ្ឋានដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងចំពោះសក្ខីកម្មរបស់សាក្សីនេះ។

35. បន្ទាប់ពីបានពិចារណាដោយយកចិត្តទុកដាក់លើសារណារបស់ភាគី អង្គជំនុំជម្រះកត់សម្គាល់ឃើញថា អាចមានការមន្ទិលសង្ស័យតិចតួច ហើយជាការជាក់ច្បាស់ និងមិនអាចប្រកែកបានថា កំណត់ហេតុស្ដាប់ចម្លើយថ្មីរបស់សាក្សី ឯក ហេន និង ជួន ធី ត្រូវបានបង្កើតឡើងក្រោយការជំនុំជម្រះ និងក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះនៅមុនពេលអង្គជំនុំជម្រះសាលាដំបូងចេញសេចក្ដីសង្ខេបនៃសាលក្រមរបស់ខ្លួន។ ពុំមានភាគីណាមួយត្រូវទទួលរងការស្ដីបន្ទោសឡើយសម្រាប់ការពន្យារពេលដែលបានចោទដាក់គ្នាទៅវិញទៅមកនោះ។

36. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯក ហេន និង ជួន ធី គឺជាសាក្សីសំខាន់ចំពោះការយល់ឃើញមួយចំនួន ដោយសារមានការយោងជាច្រើនទៅលើភស្តុតាងនៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ បន្ថែមលើនេះ និងជាសំខាន់ មេធាវីការពារក្ដី ខៀវ សំផន បានភ្ជាប់ទម្ងន់ក្នុងកម្រិតមួយដែលអាចពិចារណាបាន ទៅនឹងភស្តុតាងដែលមានសក្ដានុពលដោះបន្ទុកនោះ។

37. អង្គជំនុំជម្រះជឿជាក់ថា យុត្តិធម៌នឹងកើតមានប្រសិនអង្គជំនុំជម្រះចាប់យកទស្សនៈទូលំទូលាយនៃឆន្ទានុសិទ្ធិដែលខ្លួនមានក្នុងការទទួលយកភស្តុតាងបន្ថែមដែល ខៀវ សំផន បានលើកឡើងថា ជាភស្តុតាងដោះបន្ទុក និងថា មេធាវីការពារក្ដីបានលើកឡើងថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបាន

[50] សេចក្ដីសម្រេចលើសំណើពាក់ព័ន្ធទៅនឹងវិធាន ៨៧(៤) ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារលេខ E421/4 កថាខណ្ឌ ៩។

ពិចារណាលើភស្តុតាងនេះ អង្គជំនុំជម្រះអាចនឹងធ្វើការសន្និដ្ឋានមួយផ្សេង នៅក្នុងការសម្រេចទោសមកលើ ខៀវ សំផន។ អង្គជំនុំជម្រះពុំអាចសម្រេចដោយផ្អែកលើការលើកឡើងនេះបានឡើយ ប៉ុន្តែអង្គជំនុំជម្រះ នឹងត្រូវទទួលយកភស្តុតាងនៅក្នុងកាលៈទេសៈដែលមានការដាក់រួមជាមួយនឹងឯកសារជាច្រើនដទៃទៀតក្នុងរយៈពេលមួយបន្ទាប់ពីការដាក់ភស្តុតាងត្រូវបញ្ចប់ និងនៅពេលកាលបរិច្ឆេទសម្រាប់ដាក់ភស្តុតាងបន្ថែមបានបញ្ចប់។ ដោយផ្អែកលើវិធានផ្ទៃក្នុង ភស្តុតាងបន្ថែមគប្បីត្រូវបានដាក់ក្នុងរយៈពេល ១៥ ថ្ងៃគិតចាប់ពីពេលជូនដំណឹងនៃសេចក្តីសម្រេចនេះ។

38. អង្គជំនុំជម្រះឆ្លៀតឱកាសនេះធ្វើការកត់សម្គាល់ដោយក្តីសោកស្តាយចំពោះការប្រើប្រាស់ជាញឹកញាប់នូវភាសាមិនគួរសម និងពាក្យពេចន៍នៅក្នុងសារណារបស់មេធាវីការពារក្តី។ ពាក្យពេចន៍ទាំងនោះប្រើប្រាស់សំដៅលើអង្គជំនុំជម្រះនានា និងក្រុមផ្នែកច្បាប់ដែលប្រឆាំងនឹងខ្លួន។ អង្គជំនុំជម្រះក្រើនរំលឹកមេធាវីថា កាតព្វកិច្ចរបស់មេធាវីចំពោះកូនក្តី និងចំពោះតុលាការក្នុងការបំពេញវិជ្ជាជីវៈ រួមបញ្ចូលនូវការជៀសវាងការវាយប្រហារជាលក្ខណៈបុគ្គល និងការប្រើពាក្យធ្ងន់ៗ។ ក្នុងករណីដែលចៅក្រមអាចមានកំហុសនៅពេលមានទស្សនៈផ្ទុយត្រូវបានបង្ហាញ អង្គជំនុំជម្រះរំលឹកថា យុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល មានអត្ថិភាពយ៉ាងពិសេសក្នុងការដោះស្រាយលើកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ។ ជាការរំពឹងទុកថា កំហុសទាំងនោះអាចត្រូវបានបង្ហាញដោយមេធាវីមានកេរ្តិ៍ឈ្មោះ ដូចមេធាវីទាំងឡាយដែលបានបង្ហាញនៅក្នុងរឿងក្តីនេះ និងអ្នកដែលទទួលបានបុព្វសិទ្ធិធ្វើជាតំណាងការពារកូនក្តីរបស់ខ្លួនក្នុងកិច្ចដំណើរការនីតិវិធីសំខាន់ៗ ដែលការធ្វើបែបនេះដោយគ្មានការប្រើប្រាស់ភាសាមិនសមគួរ និងចង់គំនុំ។ អង្គជំនុំជម្រះធ្វើការព្រមានមេធាវីការពារក្តី និងសង្ឃឹមថា អ្វីដែលបានកើតឡើងនោះនឹងត្រូវបញ្ឈប់ជាបន្ទាន់ ហើយរាល់សារណានាពេលអនាគតត្រូវជៀសវាងការលើកឡើងដោយគំនុំគុំកួនចំពោះសកម្មភាពណាមួយរបស់មេធាវី ឬអង្គជំនុំជម្រះ។

## VII. ផ្នែកសម្រេចសេចក្តី

39. យោងតាមសម្អាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូល៖**

**សម្រេច**ទទួលយកសំណើនេះ

**សម្រេច**ទទួលយកភស្តុតាងបន្ថែមដូចខាងក្រោម និងខ្សែអាត់ថតសំលេងនៃភស្តុតាងនេះ

| **សម្ភារៈ** | **លេខឯកសារ** |
|---|---|
| **កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក ហេន** | E319/71.2.7 |
| **កំណត់ហេតុស្តាប់ចម្លើយរបស់ ជួន ធី** | E319/71.2.4 |

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២០

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

E.C.C.C * C.E.T.C

**គង់ ស្រ៊ីម**